

# ឯ.ឧ. នុតណារ៉ាង

(១៩៣៧-២០២៣)

*រៀបរៀងដោយ*

*បណ្ឌិតសភាចារ្យ* **ឃីងហុកឌី**

*កើតនៅខេត្តក្រចេះនាឆ្នាំ១៩៣៧ក្នុងគ្រួសារអ្នកមានសម្បត្តិ។ បិតាមានមុខរបរជាពាណិជឈើ ម្នាក់មានមុខមាត់ក្នុងខេត្តនេះ។*

*សព្វថ្ងៃលោកសល់ប្អូនស្រីពីរនាក់និងប្អូនប្រុសម្នាក់រស់នៅប្រទេសកម្ពុជាសព្វថ្ងៃនេះគឺ៖*

*-អ្នកស្រីនុតគីមឡាយដែលធ្លាប់មានតួនាទីជាប្រធានសមាគមនារីនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា។   អ្នកស្រីជាសមាជិកគណកម្មការកណ្តាលបក្សកុម្មុយ*

និស្ដកម្មជាសម័យនោះ។

-អ្នកស្រីនុតចន្ទា

-លោកនុតសម្បត្តិជាវេជ្ជបណ្ឌិត។

លោកនុតណារ៉ាង ជាអ្នកនយោបាយកម្ពុជា ដែលមានឯកទេសផ្នែកវប្បធម៌អរិយធម៌ខ្មែរហើយលោកបានទទួលការតែងតាំងជារដ្ឋលេខាធិការ ហើយ បន្ទាប់មកបានទទួល នាទីជារដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនាពេលដែល ប្រាសាទអង្គរបានបញ្ចូលក្នុង UNESCO ជាបេតិកភណ្ឌពិភពលោកនាឆ្នាំ១៩៩២ ។

នៅឆ្នាំ១៩៩៨ លោកនុតណារ៉ាងបានបញ្ចូលជាផ្លូវការ ក្នុងកម្មវិធីបុណ្យជាតិ គឺជា«ទិវាវប្បធម៌ជាតិ»។ នាពេលដែលព្រះអង្គម្ចាស់ក្សត្រីនរោត្តមបុប្ផាទេវីព្រះអង្គបាន

ទទួលការតែងតាំងជារដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ លោកនុតណារ៉ាង បានដឹកនាំ«របាំព្រះរាជទ្រព្យ»រួមជាមួយព្រះអង្គម្ចាស់ក្សត្រីនរោត្តមបុប្ផាទេវីដែរ។

បន្ទាប់ពីអស់អាណត្តិជារដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈអាណត្តិទី១ (ឆ្នាំ១៩៩៣-១៩៩៨) លោកមកបានទទួលការតែងតាំង ជាអគ្គរាជទូតប្រចាំអ៊ុយនេស្កូ (UNESCO) នៅក្រុងប៉ារីស។ បន្ទាប់ពីអស់អាណត្តិជាអគ្គរាជទូតប្រចាំអ៊ុយនេស្កូ មកលោកបានបន្តមុខងារជាជាអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំក្រុងប៉ារីសរហូតដល់ចូលនិវត្តន៍។

លោក នុត ណារ៉ាង អតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាណត្តិទី១ (ឆ្នាំ១៩៩៣-១៩៩៨) បានទទួលមរណភាព នៅថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង៩យប់ ក្នុងជន្មាយុ ៨៧ឆ្នាំ ដោយរោគាពាធ។

លោកបានទទួលមរណភាពនៅក្នុងមន្ទីរពេទ្យ Hôpital suisse de Paris ប្រទេសបារាំង។

នៅពេលស្ថានភាពខ្មៅងងឹតក្នុងប្រវត្តិសាស្ត្រកម្ពុជា លោកនុតណារ៉ាំងបានបង្កើតជាមួយមិត្តភក្តិ បារាំងខ្មែរមួយចំនួនរស់នៅប្រទេសបារាំង នូវសមាគមវប្បធម៌មួយ ដែលមានទីតាំងនៅក្រុងប៉ារីស ជិតសាកលវិទ្យាល័យស្ពរបោន (Université de la Sorbonne) នៅវិថីសាំងហ្សាកលេខ២១៨ក្នុងប៉ារីសទី៥ (218, rue Saint-Jacques 75005 Paris) ដោយប្រសិទ្ធនាមថា «មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ«ហើយលោកនុតណារ៉ាំងជាប្រធាន ពីឆ្នាំ១៩៧៥រហូតមក។[1]

## ការសិក្សាស្រាវជ្រាវ

យុវជននុតណារ៉ាំងបន្ទាប់ពីបានទទួលសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិទី២មកបានមកបន្តវិជ្ជានៅប្រទេសបារាំងហើយបានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រអក្សរសាស្ត្រ ហើយបានបន្តវិជ្ជាយកសញ្ញាប័ត្រសិក្សាជាន់ខ្ពស់ផ្នែកទេសចរ (DES) ហើយបានសិក្សានៅសាលាអនុវត្តន៍សិក្សាជាន់ខ្ពស់(Ecole Pratique des Hautes Etudes) លើសាសនានៅអាស៊ីអគ្នេយ៍ក្រោមការដឹកនាំ ដោយ សាស្ត្រាចារ្យ ប៉ូលលើវី (Paul LEVY)រហូតដល់បានជាអ្នកបង្រៀនជំនួយសាស្ត្រាចារ្យធំនេះ ពីឆ្នាំ១៩៧២ដល់១៩៧៥ គឺរហូតដល់ សាស្ត្រាចារ្យ ប៉ូលលើវី ចូលនិវត្តន៍ ជាស្ថាពរ។[2]

---

[1] សូមអានបន្ថែម សំណេរអ្នកស្រាវជ្រាវបរទេស៖ Raoul M. JENNAR, *Les clés du Cambodge*, Paris, Maisonneuve&Larose,1995 (Nouth Narang, p. 237) ; Justin CORFIELD and Laura SUMMERS, *Historical Dictionary of Cambodia,* Lanham, Maryland and Oxford, The Scarecrow, 2003 (Nouth Narang, p. 302)

[2] សូមអានរបាយណ៍ការសាលាអនុវត្តន៍សិក្សាជាន់ខ្ពស់(Ecole Pratique des Hautes Etudes)ឆ្នាំ១៩៧៤,១៩៧៥,១៩៧៦និងឆ្នាំ១៩៧៧.៖ ephe_000-0002_1974num, ephe1975, 1977.

*លោកនុតណារ៉ាំងបានដឹកនាំជាប្រធាន«មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ« ពីឆ្នាំ១៩៧៥ដល់១៩៩២ នៅប៉ារីស ហើយលោកបានទៅប្រទេសកម្ពុជាដើម្បីចូលរួមចំណែកនយោបាយក្នុងរដ្ឋាភិបាល។ នៅស្ថាប័ននេះលោកនុតណារ៉ាំងនិងក្រុមស្រាវជ្រាវបានបង្កើត ទស្សនាវដ្ដី និងបោះពុម្ពសៀវភៅ១ចំនួន (ដូចមានបញ្ជាក់ក្នុងឧបសម្ពន្ធ)។*

## *ជីវិតគ្រួសារ*

*នៅក្រុងប៉ារីសលោកនុតណារ៉ាំងបានរៀបការជាមួយ អ្នកស្រី* **ជារី** *ជាបុត្រី ឯ.ឧ.សុនរឹនសៃ[3] តែឥតមានបុត្រធីតាទេ។ អ្នកស្រីបានលាចាកលោកនេះដោយរោគាពាធ នាពេលដែលលោកនុតណារ៉ាំងត្រឡប់ទៅធ្វើការនៅប្រទេសកម្ពុជា។*

*ក្នុងសមាគម «មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ« អ្នកស្រី* **ជារី** *មានសកម្មភាពជួយអប់រំកុមារនិងទំនុកបម្រុងបាយទឹកម្ហូបអាហារដល់អ្នកចូលរួមវិស្សមកាលនៅមាត់សមុទ្រ«មេឌីទេរ៉ាណេ»ដូចមានរូបថតខ្លះៗបង្ហាញខាងក្រោមនេះ* (1984)។ *ក្នុងរូបថតនេះមានកុមារមួយចំនួនដែលសព្វថ្ងៃមានគ្រួសារសឹងគ្រប់គ្នា។ យើងនាំគ្នាដំឡើងជំរំរួមហើយ ការធ្វើម្ហូបអាហារប្រចាំថ្ងៃមានរៀបបាយទឹកលាងចានឆ្នាំគឺដាក់វេនគ្នាហើយយើងហូបរួមគ្នាជារៀងរាល់ថ្ងៃដែរ។*

---

[3] *ជាបុត្រី ភរិយាលោកនាម គីមអេងមីមី នឹងលោក ឈឹមស៊ុម។ដូចនេះភរិយាលោកនុតណារ៉ាំងនាម* **ឈឹមជារី**។*ឯ.ឧ.សុនរឹនសៃ ជាស្វាមីទី២អ្នកស្រី គីមអេងមីមី។*



Camp vacances CEDORECK été 1984









លោកនុតណារ៉ាំងមានភរិយាទី២នាមអ្នកស្រីសូភីៗមានបុត្រធីតាហើយ។[4] រស់នៅជាច្រើនឆ្នាំក្រោយមកលោកនុតណារ៉ាំងបានយកចៅស្រីអ្នកស្រីសូភីមកចិញ្ចឹមជាកូនពេញច្បាប់នាមនុតសោភារី ព្រោះលោកឥតកូន ហើយដោយមានបំណងទុកទ្រព្យសម្បត្តិឲ្យកូនចិញ្ចឹមពេញច្បាប់នេះដើម្បីតត្រកូលទៅមុខ។




លោកនុតណារ៉ាំងនិងភរិយាអ្នកស្រីសូភី

[4] សូមអានដំណឹងមរណភាពភ្ជាប់ខាងក្រោមនេះ។



*លោកនុតណារ៉ាង និងបុគ្គលិកស្ថានទូតប្រទេសកម្ពុជាប្រចាំប្រទេសបារាំង។*



**ដំណឹងមរណៈភាព**

**ឯកឧត្តម នុត ណារ៉ាង**

| | | |
|---|---|---|
| លោកជំទាវ | **នុត សុតី** | ជា ភរិយា |
| កញ្ញា | **នុត សោតារី** | ជា កូន |
| លោក | **និរ សិរីរតនា** | ជា កូន |
| លោកស្រី | **និរ សិរីសោភា** | ជា កូន |
| លោក | **និរ សិរីសុមន្ទី** | ជាកូន |

**មានទុក្ខជាទម្ងន់ដោយ**

ឯកឧត្តម **នុត ណារ៉ាង** ដែលត្រូវជាស្វាមី និងជាឪពុក
បានទទួលមរណៈភាពកាលពី **ថ្ងៃពុធ ទី៩ ខែសីហា ឆ្នាំ២០២៣**
ត្រូវនឹង**ថ្ងៃទី៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧** វេលាម៉ោង ៩ យប់
ក្នុងជន្មាយុ **៨៧ ឆ្នាំ** ដោយរោគាពាធ **នៅមន្ទីរពេទ្យ Hôpital Suisse de Paris**។

**ដំណឹងនេះចាត់ទុកជាសេចក្តីជូនដំណឹង**

ចំពោះ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី
ព្រមទាំងញាតិមិត្តជិតឆ្ងាយ នៃសព ឯកឧត្តម **នុត ណារ៉ាង** មេត្តាជ្រាបជាមការគួរ។

**កម្មវិធី ពេលវេលា និងទីកន្លែង នៃការរៀបចំប្រារព្ធពិធីបុណ្យសព**
**មានទុកលថ្វាយ និងជម្រាបជូនជាក្រោយ។**

ថ្ងៃព្រហស្បតិ៍ ៩រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ត្រូវនឹងថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៣

*ដំណឹងមរណៈភាព*

# ការងារតួនាទីក្នុងបក្សនយោបាយ

លោកនុតណារ៉ាំងបានត្រឡប់ទៅកម្ពុជាវិញដើម្បីចូលរួមចំណែកក្នុងឆាកនយោបាយស្រុកទេស។

លោកបានចូលជាសមាជិកបក្សកុម្មុយនិស្តកម្ពុជានាឆ្នាំ១៩៩៧។លោកបានទទួលតួនាទីដំបូងជារដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈហើយបន្ទាប់បានឡើងតួនាទីជារដ្ឋមន្ត្រីនៅក្រសួងដដែលនេះ។



រូបចម្លាក់សិល្បៈខ្មែរនៅបរទេសបានប្រគល់ត្រឡប់មកប្រទេសកម្ពុជាវិញ។



លោកនុតណារ៉ាង ព្រះអង្គម្ចាស់ក្សត្រី នរោត្តមបុប្ផាទេវី បណ្ឌិតប៉ែនសេដ្ឋារិន
(រូបកម្មសិទ្ធសាស្ត្រាចារ្យប៉ែនសេដ្ឋរិន)។




នាពេលដែលព្រះអង្គម្ចាស់ក្សត្រីបុប្ផាទេវីជារដ្ឋមន្ត្រីក្រសួងវប្បធម៌លោកនុតណារ៉ាងលោកបានចូលរួម
សិក្ខាសាលានានាដូច ជាសិក្ខាសាលា«ប៉ូលប៊ូដេត៍» នៅបណ្ណាល័យជាតិកម្ពុជា នៅឆ្នាំ២០០១ជាដើម
(រូបកម្មសិទ្ធ យហឱ)។



*បុណ្យខួប១០០ថ្ងៃនៃមរណភាពលោកនុតណារ៉ាង*
*ក្នុងវត្តសុវណ្ណភូមិនៅវីទ្រីស៊្ឬរសែន (Vitry/Seine) ក្រោមអធិបតីភាពរាជទូតប្រទេសកម្ពុជាប្រចាំក្រុងប៉ារីស។*

## *ឧបសម្ព័ន្ធ*

## *ស្នាដៃលោកនុតណារ៉ាង*
## *រួមជាមួយសហការីនានា៖*

*ទស្សនាវដ្ដីដែលមានកំណើតនៅសមាគម«មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ«គឺ៖*

- *ទស្សនាវដ្ដី «សិក្សាខ្មែរ» (គឺជាទស្សនាវដ្ដីស្រាវជ្រាវ ជាភាសាបារាំង)*
- *ទស្សនាវដ្ដី «កូនខ្មែរ»ព្រឹត្តិប័ត្រប្រចាំឆមាស «វប្បធម៌ខ្មែរ»*

- *សមូហកម្មអត្ថបទអក្សរសិល្ប៍ ដឹកនាំដោយបណ្ឌិតឃីងហុកឌី បានបោះផ្សាយឡើងវិញនូវអត្ថបទអក្សរសិល្ប៍មួយចំនួននៅ«មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ« ក្រុងប៉ារីស ដូចជា«ច្បាប់ផ្សេងៗ, រឿងហង្សយន្ត, កុលាបប៉ៃលិន, ផ្កាស្រពោន, មាលាដួងចិត្ត ជាដើម។*
- ***សមូហកម្ម ដោយដាក់ចំណងជើងថា«បណ្ណាល័យខ្មែរ»***
  *ដែលបានផ្សាយហើយគឺមាន*
- «*ពពិល*, *Le Polpil : Objet Rituel Cambodgien* (Solange THIERRY), Paris, Cedoreck, 126 p.
- *Le Roman cambodgien du Lièvre*, *សុភាទន្សាយ*, Présentation par Jacques NEPOTE, Ed. bilingue, *២ភាសា គឺខ្មែរ បារាំង*, Paris, Cedoreck, 1984, 81 p.
- *Notes sur les coutumes et croyances superstitieuses des Cambodgiens*, commenté et présenté par Saveros POU, Paris, Cedoreck, 1984,116 p.
- ANG Chouléan, *Les êtres surnaturels dans la religion populaire khmère*, préface de G. Condominas, Paris, Cedoreck, 1986, 349 p.
- Saveros POU, *Guirlande de Cpàp'*, Paris, Cedoreck,1988, 2 tomes.
- Saveros POU, *Dictionnaire : Vieux khmer, Français, Anglais,* Paris, Cedoreck, 1992, 555p.

## *បោះផ្សាយឡើងវិញសៀវភៅសំខាន់សម្រាប់អ្នកស្រាវជ្រាវ៖*

- Lunet de LAJONQUIERE, *Inventaire descriptif des monuments du Cambodge*, tome1, PHNOM PENH, CEDORECK, 2001, 430 p.
- Paul COLLARD, *Cambodge et Cambodgiens,* PHNOM PENH, CEDORECK, 2001, 312 p.

- ប៉ែណារ ហ្វីលីប ប្រហ្គាសលីយេ, *ទីក្រុងទឹកអង្គរ ជំហរអារ្យធម៌ខ្មែរ*,បុព្វបទដោយឯកឧត្តម អ៊ឹមឈុនលឹម, ភ្នំពេញ, «មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ«, ២០០៣,៣៥២ ទំព័រ។
- ឃីងហុកឌី, *អក្សរសាស្ត្រខ្មែរ*, អារម្ភកថាដោយនុតណារ៉ាង, ភ្នំពេញ, «មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ«, ២០០៣,២០០ទំព័រ+រូបថត។
- សុងស៊ីវ. នួនប៊ុត. សមសុខ, ជុំ មួង, *ក្បួនមហាទក្សា និង គំរូឲ្យឈ្មោះហាង*. កថាមុខដោយនុតណារ៉ាង, «មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ«, ២០០៣, ១២៥ទំព័រ។
- ហង្សក ប្រហ្គាសលីយេ, *គំនូរខ្មែរទាំង៧៦*,«មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ«, ២០០៣,៧៤ទំព័រ។

## សំណេរជាភាសាបារាំងសហការៈ

- Michel Butor & Nouth Narang, *Angkor silencieux*, Paris, 1988, 168 p.

,



រូបក្របឯកសារខ្លះៗ៖




ទស្សនាវដ្ដីស្រាវជ្រាវ «សិក្សាខ្មែរ»




ទស្សនាវដ្ដីវប្បធម៌«កូនខ្មែរ»




អត្ថបទអក្សរសិល្ប៍ដែលបោះផ្សាយឡើងវិញនៅក្រុងប៉ារីស។




ទិដ្ឋភាពទូទៅអក្សរសាស្ត្រខ្មែរផ្សាយឡើងវិញ
ឆ្នាំ២០០៣នៅភ្នំពេញ។




សមុហកម្មសៀវភៅស្រាវជ្រាវពីវប្បធម៌អារ្យធម៌ខ្មែរ បោះពុម្ពនៅប៉ារីស។




ព្រឹត្តិប័ត្រវប្បធម៌ខ្មែរ ប្រចាំឆមាស បោះផ្សាយនៅប៉ារីស។







ការបោះពុម្ពផ្សាយដោយលោកនុតណារ៉ាំង នៅភ្នំពេញឆ្នាំ២០០៣។

# សាររំលែកទុក្ខដោយវរជនកំពូលៗក្នុងព្រះរាជាណាចក្រកម្ពុជា៖

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សាររំលែកទុក្ខ**
**ផ្ញើជូន**
**លោកជំទាវ នុត សុតី**

***លោកជំទាវ ជាទីរាប់អាន***

ខ្ញុំ និងភរិយាមានក្ដីរំជួលចិត្តឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា ឯកឧត្តម **នុត ណារ៉ាង** អតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អតីតឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសបារាំង និងជាឯកអគ្គរាជទូតប្រតិភូអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការយូណេស្កូ ត្រូវជាស្វាមីរបស់លោកជំទាវបានទទួលមរណភាព កាលពីវេលាម៉ោង ២១៖០០នាទី យប់ ថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ ក្នុងជន្មាយុ ៨៧ឆ្នាំ ដោយរោគាពាធ។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងភរិយាសូមសម្ដែងនូវការសោកស្ដាយស្រណោះ អាឡោះអាល័យជាទីបំផុតជាមួយលោកជំទាវ ចំពោះការបាត់បង់ឯកឧត្ដម **នុត ណារ៉ាង** ដែលត្រូវជាស្វាមី ឪពុក ឪពុកក្មេក ជីតា ពោរពេញដោយព្រហ្មវិហារធម៌មិនចេះរីងស្ងួត ចំពោះកូនៗ ចៅៗជាទីស្រឡាញ់។

មរណភាពរបស់ឯកឧត្តម **នុត ណារ៉ាង** ជាការបាត់បង់ដ៏ធំធេងនូវឥស្សរជនមួយរូប ដែលបានលះបង់កម្លាំងកាយ ចិត្តនិងបញ្ញាស្មារតី ក្នុងការចូលរួមចំណែកការពារ ថែរក្សានិងលើកតម្លៃបេតិកភណ្ឌវប្បធម៌ និងសម្បត្តិវប្បធម៌ជាតិ ដើម្បីអភិវឌ្ឍន៍វិស័យវប្បធម៌ និងជំនឿទំនៀមទម្លាប់ ប្រពៃណីរបស់ព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវដែលបានពាំនាំបណ្ដាំរបស់ឯកឧត្តម **នុត ណារ៉ាង** ប្រកបដោយពាក្យពេចន៍ដែលពោរពេញដោយមនោសញ្ចេតនានិងការជឿទុកចិត្ត បន្តគាំទ្រដល់រាជរដ្ឋាភិបាលនិងគណបក្សប្រជាជនកម្ពុជា។

ខ្ញុំ និងភរិយាសូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធឯកឧត្តម **នុត ណារ៉ាង** សូមឆាប់បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូមលោកជំទាវទទួលនូវមនោសញ្ចេតនារំលែកទុក្ខដ៏ក្រៀមក្រំពី ខ្ញុំ និងភរិយា។

ថ្ងៃសៅរ៍ ១១រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣

**ហ៊ុន សែន**

*សារសម្ដេចអគ្គមហាសេនាធិបតី ហ៊ុនសែន*

ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតរំលែកទុក្ខ

**ជូនចំពោះ**
**លោកជំទាវ នុត សុគី និងក្រុមគ្រួសារ**

***លោកជំទាវ*** *ជាទីរាប់អាន*

ខ្ញុំ និងភរិយា មានសេចក្តីសោកស្តាយយ៉ាងខ្លាំង ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា**ឯកឧត្តម នុត ណារ៉ាង** អតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវជាស្វាមីរបស់**លោកជំទាវ** បានទទួលមរណភាព នៅថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង៩:០០យប់ ក្នុងជន្មាយុ ៨៧ឆ្នាំ ដោយរោគាពាធ នៅប្រទេសបារាំង។

មរណភាពរបស់**ឯកឧត្តម នុត ណារ៉ាង** គឺជាការបាត់បង់កុលបុត្រខ្មែរមួយរូប បានយកអស់កម្លាំងកាយចិត្ត បញ្ញា និងស្មារតី ចូលរួមអភិរក្ស អភិវឌ្ឍន៍វិស័យវប្បធម៌ អរិយធម៌ ដ៏រុងរឿងរបស់កម្ពុជា។

ខ្ញុំ និងភរិយា សូមចូលរួមរំលែកទុក្ខជាមួយ**លោកជំទាវ** ព្រមទាំងក្រុមគ្រួសារចំពោះការបាត់បង់ស្វាមី ឪពុក ជាទីគោរពស្រលាញ់ប្រកបដោយសង្គហធម៌ និងព្រហ្មវិហារធម៌ដ៏ល្អប្រពៃ។ ទោះបីរូបកាយរបស់**ឯកឧត្តម** បានបាត់បង់ទៅមែនពិត ប៉ុន្តែកិត្តិយស សេចក្តីថ្លៃថ្នូរ ភាពអំណត់ តស៊ូនឹងនៅស្ថិតស្ថេរក្នុងចិត្តកូន ចៅ និងញាតិមិត្តជិតឆ្ងាយទាំងអស់ជានិច្ចនិរន្តរ៍។

សូមវត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមជួយបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធ **ឯកឧត្តម** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ ទទួលនូវមនោសញ្ចេតនាចែករំលែកទុក្ខដោយក្តីក្រៀមក្រំពីខ្ញុំ និងភរិយា។

ថ្ងៃ *សុក្រ ១០រោច* ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២៣

(signature)

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

*សាររំលែកទុក្ខសម្តេចវិបុសសេមាកក្តីសាយឈុំ*

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្ដាល

យុវជនគណបក្សថ្នាក់កណ្ដាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

**សាររំលែកទុក្ខ**

**ជូនចំពោះ**

**លោកជំទាវ នុត សុតី ព្រមទាំងក្រុមគ្រួសារ**
**ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ**

ក្នុងនាមខ្ញុំផ្ទាល់ ក៏ដូចជាយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល យើងខ្ញុំសូមសម្តែងនូវសមានទុក្ខដ៏ក្រៀមក្រំ និងភាពក្តុកក្តួលរំជួលចិត្តយ៉ាងខ្លាំង ជូនចំពោះ **លោកជំទាវ នុត សុតី** ព្រមទាំងក្រុមគ្រួសារ អំពីដំណឹងនៃការបាត់បង់ **ឯកឧត្តម នុត ណារ៉ាង** អតីតឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំ **សាធារណរដ្ឋបារាំង** ត្រូវជាឧត្តមស្វាមីរបស់លោកជំទាវ ដែលបានទទួលអនិច្ចកម្ម **កាលពីថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣** ក្នុងជន្មាយុ **៨៧ឆ្នាំ** ដោយរោគាពាធ។

មរណភាពរបស់ **ឯកឧត្តម នុត ណារ៉ាង** គឺការបាត់បង់នូវឧត្តមស្វាមី លោកឪពុក លោកឪពុកក្មេក និងជីតា ជាទីគោរពស្រឡាញ់បំផុតរបស់ក្រុមគ្រួសារ ព្រមទាំងបងប្អូនកូនក្មួយ និងជាអ្នកមានគុណមួយរូបផ្តល់នូវភាពកក់ក្តៅក្នុងក្រុមគ្រួសារ ប្រកបទៅដោយព្រហ្មវិហារធម៌សព្វគ្រប់បែបយ៉ាង ដែលបានបូជាកម្លាំងកាយ កម្លាំងចិត្ត នៅក្នុងការបីបាច់ថែរក្សាអប់រំទូន្មាន បុត្រា បុត្រី ចៅៗ និងក្មួយៗ ឲ្យក្លាយទៅជាពលរដ្ឋល្អដើម្បីចូលរួមគ្រប់សកម្មភាពនៃការអភិវឌ្ឍសង្គម និងបុព្វហេតុសុខសន្តិភាពរបស់ប្រទេសជាតិ។

ក្នុងឱកាសប្រកបដោយក្តីខ្សឹកខ្សួលរំជួលចិត្តជាអនេកនេះ យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកមរណទុក្ខដ៏សែនក្រៀមក្រំយ៉ាងក្រៃលែង និងពោរពេញដោយក្តីសោកស្តាយស្រណោះអាឡោះអាល័យបំផុត ជាមួយ **លោកជំទាវ នុត សុតី** ព្រមទាំងក្រុមគ្រួសារ និងសូមឧទ្ទិសបួងសួងដួងវិញ្ញាណក្ខន្ធ **ឯកឧត្តម នុត ណារ៉ាង** សូមបានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតក្លាយជាបការៈដទៃឡើយ។

សូម **លោកជំទាវ នុត សុតី** ព្រមទាំងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំ និងសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ អំពីយើងខ្ញុំ៕

ថ្ងៃសុក្រ ១០រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣
**ជ.យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល**
**ប្រធាន**

**កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត**

*សាររំលែកទុក្ខ កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត*